# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

## មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ

## និង

## អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន (RCEDO) និង

## អង្គការអភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO)

**១.សេចក្តីផ្តើមៈ**

អនុស្សារណៈយោគយល់នេះ គឺដើម្បីបង្កើតអោយមាន កិច្ចសហប្រតិបត្តិការរវាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយ អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន (RCEDO) និង អង្គការ អភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO) តាមរយៈ ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍ ជំហ៊ាន ២ ខែមេសា ២០១៨ ដល់ ខែមិនា ២០២១។

គោលបំណង គឺ ចូលរួមចំណែកធ្វើឲ្យប្រជាពលរដ្ឋក្នុងសហគមន៍កាន់តែមានលទ្ធភាពទទួលនូវការលើកកម្ពស់ជីវភាពរស់នៅតាមរយៈការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិ ដោយការដាំដុះដំណាំស្រូវ បន្លែ និងការចិញ្ចឹមសត្វ ដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុជាពិសេសគ្រោះមហន្តរាយទឹកជំនន់ និង រាំងស្ងួត ។ កិច្ចសហប្រតិបត្តិការនេះ នឹងធ្វើអោយការអនុវត្តគម្រោង(CBDRR-II) កាន់តែមានប្រសិទ្ធភាព និង សំរេចបាននូវគោលដៅរួមរបស់គម្រោង ដែលស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ស្តីពីការបញ្ជ្រាបដោយប្រសិទ្ធភាពនូវការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងដំណើរការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចគ្រប់កម្រិត។

**២. គោលបំណង នៃកិច្ចសហប្រតិបត្តិការៈ**

១-ពង្រឹងកិច្ចសហការជាដៃគូ ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍ ។

២-ផ្តល់ជំនួយបច្ចេកទេស និងការអនុវត្តបង្ហាញជាក់ស្តែងដល់កសិករ អំពីការដាំដុះដំណាំស្រូវដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ការដាំបន្លែសេរីរាង្គ និងការចិញ្ចឹមសត្វដែលមានភាពធន់នឹងអាកាសធាតុ ។

៣-ជំរុញ និង សម្របសម្រួលក្នុងការបង្កើតសហគមន៍ស្រូវ បន្លែសិរីរាង្គ និងសត្វដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

៤-ចូលរួមត្រួតពិនិត្យ តាមដាន និង ផ្តល់អនុសាសន៍ដើម្បីអោយសកម្មភាពគម្រោងដែលទាក់ទងវិស័យកសិកម្មកាន់តែប្រសើរឡើង ។

**៣. លទ្ធផលរំពឹងទុកនៃកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តគម្រោងៈ**

១)-ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍មានដំណើរការល្អ មានប្រសិទ្ធភាព និងនិរន្តរភាពគម្រោង ។

២)-ប្រជាកសិករមានចំណេះដឹង និងសមត្ថភាព ក្នុងការដាំដុះដំណាំស្រូវ បន្លែ និងការចិញ្ចឹមសត្វ តាមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងដើម្បីធ្វើឲ្យប្រសើរឡើងនូវផលិតកម្មកសិកម្ម និង បង្កើនប្រាក់ចំណូលរបស់កសិករ។

៣)-សហគមន៍ស្រូវ បន្លែសិរីវង្គ និងសត្វដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើង និងមានដំណើរការនៅក្នុងសហគមន៍គោលដៅ នៃ គម្រោង CBDRR ។

៤)-ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយមានប្រសិទ្ធភាពស្របតាមគោលនយោបាយ និង បទដ្ឋានរបស់រាជរដ្ឋាភិបាល ។

## ៤.ប្រវត្តគម្រោង ៖

គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហគមន៍ (CBDRR)បានចាប់អនុវត្តក្នុងខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៤-២០១៧ ដែលគាំទ្រថវិកាដោយ អង្គការ CARITAS នៃប្រទេសស្វីស (Switzerland) ដែលបានអនុវត្តដោយ អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន (RCEDO) ជាមួយនិង អង្គការអភិវឌ្ឍន៍សង្គម បរិស្ថាន និងកសិកម្ម (SEADO) ស្ថិតនៅក្នុងឃុំចំនួន៦ លើស្រុកចំនួន៣ (ស្រុកស្វាយចេក ស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី) នៃខេត្តបន្ទាយមានជ័យ ។ ដោយឡែកសំរាប់គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហគមន៍(CBDRR) ជំហ៊ាន២ ចាប់ពី ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២១ នឹងបន្តអនុវត្តដោយអង្គការដៃគូរទាំងពីរ (SEADO&RCEDO) ក្នុងភូមិគោលដៅចំនួន ៥០ ឃុំចំនួន ៧ លើស្រុកចំនួន៣ (ស្រុកស្វាយចេក ស្រុកព្រះនេត្រព្រះ និង មង្គលបូរី ) នៃ ខេត្តបន្ទាយមានជ័យ។ ដើម្បីអនុវត្តគម្រោងនេះ អោយមានប្រសិទ្ធភាព និងសំរេចបានជោគជ័យ អង្គការ អាសេដូ និង ស៊ីដូ បានលើកកម្ពស់ការសហការជាមួយមន្ទីរពាក់ព័ន្ធ ដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរអប់រំយុវជន និងកីឡា មន្ទីរធនធានទឹក និងឧតុនិយម ដើម្បីផ្តល់ជំនាញបច្ចេកទេសតាមវិស័យ ការសម្របសម្រួល និងជំរុញការចូលរួមពីប្រជាពលរដ្ឋ តំណាងសហគមន៍ ក្រុមប្រឹក្សាស្រុក/ឃុំ/អាជ្ញាធរ និង ស្ថាប័នពាក់ព័ន្ធនានា ។ គម្រោងនេះគ្រោងចំណាយថវិកាសរុបរយៈពេល៣ឆ្នាំមានចំនួន $៧៥១,៨០៧.០០ (ប្រាំពីរយហាសិបមួយពាន់ ប្រាំបីរយប្រាំពីដុល្លាអាមេរិក) ដើម្បីអនុវត្តសកម្មភាពនិងសម្រេចគោលដៅគម្រោង។

ភាគីទាំងពីរមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

### ៤.១. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

- សម្របសម្រួលឲ្យមានមន្ត្រីជំនាញ និងបច្ចេកទេសចំនួន ២ ទៅ ៣រូប ដើម្បីគាំទ្រសកម្មភាពគម្រោងរយៈពេល ៣ឆ្នាំ (២០១៨-២០២១) សម្រាប់ចូលរួមចំណែកអនុវត្តគម្រោងជាមួយមន្ត្រីគម្រោងរបស់អង្គការ អាសេដូ (RCEDO) និង ស៊ីដូ (SEADO) ។
- រៀបចំមេរៀន និង ផ្តល់វគ្គបណ្តុះបណ្តាល កសាងសមត្ថភាព ចំណេះដឹង ជំនាញ និងអនុវត្តជាក់ស្តែងដល់គណៈកម្មការសហគមន៍ និង កសិករគោលដៅ ស្តីពីការដាំដុះដំណាំស្រូវ បន្លែសេរីវង្គ និង ចិញ្ចឹមសត្វដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- ជំរុញ និង សម្របសម្រួលក្នុងការបង្កើតសហគមន៍ស្រូវ បន្លែសិរីវង្គ និងសត្វដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

- ផ្តល់ការប្រឹក្សានិងពិគ្រោះយោបល់ដល់គណៈកម្មការសហគមន៍កសិករ ក្រុមជួយខ្លួនឯង និង បុគ្គលិកគម្រោងរបស់អង្គការដៃគូទាំងពីរលើការងារផលិតកម្មកសិកម្ម ។
- ចែករំលែក និង ផ្តល់ព័ត៌មាននានាដល់គណៈកម្មការសហគមន៍កសិករ រួមទាំងបុគ្គលិកគម្រោងរបស់អង្គការដៃគូ។
- ចូលរួមតាមដាន ត្រួតពិនិត្យស្តីពីការរីកចម្រើនរបស់គម្រោងអោយមានប្រសិទ្ធភាព និងនិរន្តរភាព។
- គោរពនិងបំពេញនូវកិច្ចសហប្រតិបត្តិការជាមួយបុគ្គលិករបស់អង្គការដៃគូទាំងពីរ (អាសេដូ និង ស៊ីដូ) តាមខ្លឹមសារនៃអនុស្សារណៈនេះ។
- ផ្តល់មន្ត្រីជំនាញបច្ចេកទេសចុះអនុវត្តតាមតារាងផែនការការងារដែលបានភ្ជាប់នៅឧបសម្ព័ន្ធ (ក)

**៤.២ តួនាទីនិងភារកិច្ចរបស់អង្គការ អាសេដូ និង ស៊ីដូ** (RCEDO& SEADO) ៖

- ធានាប្រសិទ្ធភាពនៃការអនុវត្តន៍សកម្មភាពគម្រោង ដោយផ្តល់និង ពន្យល់អោយបានជាក់លាក់ពីតំរូវការ ចំនួនអ្នកទទួលផល និងលទ្ធផលរំពឹងទុក។
- រៀបចំ និង គាំទ្រថវិកាដល់មន្ត្រីចុះអនុវត្តសកម្មភាពតាមគោលការណ៍របស់អង្គការដៃគូ និង ផ្អែកលើថវិកាបានអនុម័តរបស់ម្ចាស់ជំនួយ ។
- ជ្រើសរើស និង រៀបចំសម្របសម្រួលឲ្យមានកសិករចូលរួមដាំដុះដំណាំស្រូវ បន្លែសិរីវង្គ និងចិញ្ចឹមសត្វច្បាស់លាស់តាមចំនួនដែលគម្រោងបានកំណត់ ។
- ចូលរួមរៀបចំមេរៀនសម្រាប់បណ្តុះបណ្តាលសមត្ថភាពចំណេះដឹង និងជំនាញដល់គណៈកម្មការសហគមន៍កសិកម្ម និង កសិករ។
- សម្របសម្រួលរៀបចំកិច្ចប្រជុំជាមួយគណៈកម្មការសហគមន៍កសិករ និង កសិករជាប្រចាំខែ ដើម្បីតាមដានការវិវត្តន៍ នៃការអនុវត្តគម្រោង។
- សម្របសម្រួលរៀបចំដំណើរទស្សនៈកិច្ចសិក្សា ដល់គណៈកម្មការសហគមន៍ និងកសិករ ។
- គោរពនិងបំពេញការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះអនុស្សារណៈនៃការយោគយល់គ្នានេះ ក្នុងន័យពង្រឹងប្រសិទ្ធភាពក្នុងនាមភាពជាដៃគូអនុវត្តគម្រោង។

**៥.គោលការណ៍ ក្នុងការអនុវត្តន៍គម្រោង៖**

ការលើកកម្ពស់ជីវភាពរបស់កសិករក្នុងសហគមន៍ គឺជារឿងដ៏ចាំបាច់បំផុតសម្រាប់បរិបទកម្ពុជា នាពេលបច្ចុប្បន្ននេះពីព្រោះថាប្រទេសកម្ពុជា ជាប្រទេសកសិកម្ម និងដើម្បីបង្កើននូវប្រាក់ចំណូល និងធានាបាននូវសន្តិសុខស្បៀងអាហារ របស់កសិករនៅក្នុងសហគមន៍ ដូច្នេះការរួមចំណែករបស់ភាគី ដែលមាននៅក្នុងអនុស្សារណៈយោគយល់នេះពិតជាអាចជួយចូលរួមចំណែកដោះស្រាយបញ្ហា នៃការបង្កបង្កើនផលរបស់កសិករផងដែរ ។

ភាគីទាំងពីរគោរពនិងបំពេញដោយឆន្ទៈដូចជា៖

- ប្តេជ្ញាចិត្តអនុវត្តតាមដោយមានការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញតួនាទីរបស់ខ្លួន
- ធានានិងចូលរួមយ៉ាងសកម្មជាមួយនិងសកម្មភាពគម្រោងនៅពេលដែលគម្រោងត្រូវការ
- ស្តាប់ជជែកពិភាក្សាគ្នានិងអោយតម្លៃគ្នាទៅវិញទៅមកក្នុងនាមដៃគូអភិវឌ្ឍន៍ពីគ្រប់ភាគីពាក់ព័ន្ធជាពិសេសការលើកឡើងរបស់ប្រជាកសិករមូលដ្ឋាន។

- សម្របសម្រួលលើកទឹកចិត្តកសិករ ដើម្បីចូលរួមសកម្មភាពគម្រោងទៅលើការធ្វើកសិកម្ម បន្សាំនឹងការប្រែប្រួលអាកាសធាតុ ។
- គាំទ្រក្នុងការស្វែងរកធនធានបន្ថែម ដើម្បីគាំទ្រគម្រោងនៅឆ្នាំបន្តបន្ទាប់ទៀតប្រសិនបើការអនុវត្តសកម្មភាពគម្រោងទាំងអស់ខាងលើសម្រេចបានជោគជ័យ និងមានតម្រូវការពីកសិករបន្ថែមទៀត។

ក្នុងករណីមានបញ្ហាអ្វីមួយឬមានការផ្លាស់ប្តូរទាក់ទងនិងគម្រោង ភាគីទាំងពីរត្រូវជួបពិភាក្សា និងដោះស្រាយគ្នាប្រកបដោយតម្លាភាព សន្តិវិធី ដោយស្មារតីទទួលខុសត្រូវខ្ពស់ និង ស្មោះត្រង់ជឿជាក់គ្នាទៅវិញទៅមកក្នុងន័យផ្តល់ផលប្រយោជន៍ដល់ប្រជាសហគមន៍ក្នុងតំបន់គោលដៅ។ អង្គការ ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត មានសិទ្ធិសម្រេចបន្ត ឬ បញ្ឈប់កិច្ចព្រមព្រៀងនេះមុនពេលកំណត់បាន ដោយមានលិខិតជាលាយលក្ខ័អក្សរដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងសមហេតុសមផល។ ក្នុងកំឡុងពេលនៃការអនុវត្តតួនាទី និងភារកិច្ចរបស់ដៃគូឲ្យសម្រេចបាននូវលទ្ធផលដែលបានរំពឹងទុក ។ ភាគីទាំងពីរគប្បីឯកភាពអនុវត្តរួមគ្នាតាមផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗក្នុងនាមជាដៃគូសហប្រតិបត្តិការគម្រោងដូចមានភ្ជាប់មកនូវឧបសម្ព័ន្ធ(១)។

**ភាគីទាំងពីរបានយល់ព្រម**

**និង ទទួលយកគ្រប់លក្ខខណ្ឌទាំងអស់ខាងលើជាផ្លូវការដោយចុះហត្ថលេខាខាងក្រោម៖**

| មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តបន្ទាយមានជ័យ | អង្គការអភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO) | អង្គការអភិវឌ្ឍន៍សហគមន៍ ជនបទ និង បរិស្ថាន(RCEDO) |
|---|---|---|
| ឈ្មោះ ៖ ថ្វាង វណ្ណាសេដ្ឋ | ឈ្មោះ៖ គង់ សំណាង | ឈ្មោះ៖ សំ សេរីវឌ្ឍនា |
| តួនាទី ៖ ប្រធានមន្ទីរ | តួនាទី ៖ នាយកប្រតិបត្តិ | តួនាទី ៖ នាយកប្រតិបត្តិ |
| ថ្ងៃ.........................ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ | ថ្ងៃ.........................ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ | ថ្ងៃ.........................ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ |
| ប.ជ,ថ្ងៃទី...៣០...ខែ...ឧសភា...ឆ្នាំ២០១៨ | ប.ជ,ថ្ងៃទី...៣០...ខែ...ឧសភា...ឆ្នាំ២០១៨ | ប.ជ,ថ្ងៃទី...៣០...ខែ...ឧសភា...ឆ្នាំ២០១៨ |

# តារាងផែនការការងារសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ខេត្តបន្ទាយមានជ័យ ឆ្នាំ ២០១៨

| លរ | សកម្មភាព | ពេលវេលា | ចំនួនថ្ងៃ | ចំនួនលើក/ វគ្គ | ថវិកាសរុប | លទ្ធផលរំពឹងទុក | អ្នកទទួលផល | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសដាំបន្លែដែលធន់នឹងអាកាសធាតុ និង ការរៀបចំទីតាំងបង្ហាញ | ខែកក្កដា-សីហា ឆ្នាំ ២០១៨ | ៣ | ២ | ៣៦០ ដុល្លា | ប្រជាពលរដ្ឋចំនួន៤០ គ្រួសារនៅក្នុងឃុំគោលដៅចំនួន៧ នៃ៣ស្រុក របស់អង្គការ ស៊ីដូ និង អង្គការអា សេ ដូ ទទួលបានចំណេះដឹង និងមានសមត្ថភាពដាំបន្លែដែលធន់នឹងអាកាសធាតុបាន | ៤០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២ | វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមមាន់ទា និង ការរៀបចំទីតាំងបង្ហាញ | ខែសីហា ឆ្នាំ ២០១៨ | ៤ | ២ | ៤៨០ ដុល្លា | ប្រជាពលរដ្ឋចំនួន៤០ គ្រួសារនៅក្នុងឃុំគោលដៅចំនួន៧ នៃ៣ស្រុក របស់អង្គការ ស៊ីដូ និង អង្គការអា សេ ដូ ទទួលបានចំណេះដឹង និងមានសមត្ថភាពចិញ្ចឹមមាន់ ទាស្របតាមលក្ខណៈបច្ចេកទេស | ៤០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសដាំដំណាំស្រូវពូជដែលធន់នឹងអាកាសធាតុ និងការរៀបចំទីតាំងបង្ហាញ | ខែមិថុនា ឆ្នាំ ២០១៨ | ៣ | ៤ | ៧២០ ដុល្លា | ប្រជាពលរដ្ឋចំនួន៨០ គ្រួសារនៅក្នុងឃុំគោលដៅចំនួន៧ នៃ៣ស្រុក របស់អង្គការស៊ីដូ និងអង្គការអាសេដូ ទទួលបានចំណេះដឹង និងមានសមត្ថភាពដាំដំណាំស្រូវស្របតាមលក្ខណៈបច្ចេកទេស | ៨០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤ | ចុះត្រួតពិនិត្យការអនុវត្ត និងផ្សព្វផ្សាយបន្តរបស់កសិករលើការដាំបន្លែដល់គ្រួសារដទៃ | ខែកក្កដា-កញ្ញាឆ្នាំ ២០១៨ | ១ | ៦ | ១៨០ ដុល្លា | ធានាថាកសិករដែលបានទទួលចំណេះដឹងអនុវត្តការដាំបន្លែស្របតាមលក្ខណៈបច្ចេកទេស | ៤០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៥ | ចុះត្រួតពិនិត្យការអនុវត្ត និងផ្សព្វផ្សាយបន្តរបស់កសិករលើការចិញ្ចឹមមាន់ទា | ខែសីហា-កញ្ញា ឆ្នាំ ២០១៨ | ១ | ៦ | ១៨០ ដុល្លា | ធានាថាកសិករដែលបានទទួលចំណេះដឹងអនុវត្តការចិញ្ចឹមមាន់ ទា និងធ្វើទ្រុង ស្របតាមលក្ខណៈបច្ចេកទេស | ៤០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៦ | ចុះត្រួតពិនិត្យការអនុវត្ត និងផ្សព្វផ្សាយបន្ត របស់កសិករលើការដាំដំណាំស្រូវដល់គ្រួសារដទៃ | ខែមិថុនា-កក្កដា ឆ្នាំ ២០១៨ | ១ | ៦ | ១៨០ ដុល្លា | ធានាថាកសិករដែលបានទទួលចំណេះដឹងអនុវត្តការដាំដំណាំស្រូវស្របតាមលក្ខណៈ | ៨០គ្រួសារ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | បច្ចេកទេស និងទទួលបានទិន្នផលខ្ពស់ | | |
| ៧ | ចូលរួមផ្តល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសដាំដំណាំបន្លែតាមសាលារៀន | ខែតុលា-វិច្ឆិកា ឆ្នាំ ២០១៨ | ២ | ៣ | ៤៥០ ដុល្លា | លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរពាក់ព័ន្ធទទួលបានចំណេះដឹង និងមានសមត្ថភាពសម្របសម្រួលផ្ទេរចំណេះដឹងបន្តដល់សិស្សានុសិស្ស | ៨សាលា ៤០០នាក់ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨ | ចូលរួម និងគាំទ្រសកម្មភាពដាំកូនឈើ និង ទិវាផ្សេងៗ | ខែកក្កដា ឆ្នាំ ២០១៨ | ១ | ២ | ១៥០ ដុល្លា | កូនឈើចំនួន ១០០០០ ដើមត្រូវបានដាំតាមសហគមន៍ និង ប្រឡាយទឹក ក្នុងឃុំគោលដៅ | ១០០០០ដើម ក្នុង៣ស្រុក | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៩ | ផ្សព្វផ្សាយអំពីជម្ងឺផ្តាសាយបក្សី និង សត្វពាហណៈ ដល់សហគមន៍គោលដៅ | ខែតុលា-វិច្ឆិកា ឆ្នាំ ២០១៨ | ១ | ៥ | ៣០០ ដុល្លា | ប្រជាពលរដ្ឋរស់នៅក្នុងឃុំគោលដៅចំនួន៧ នៃ ៣ស្រុករបស់អង្គការស៊ីដូ និងអង្គការអាសេដូ ទទួលបានចំណេះដឹង និងអនុវត្តការត្រៀបង្ការបានពីជម្ងឺផ្តាសាយបក្សី | ២៥០នាក់ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |